ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន
លេខ:...០០៧...ស.ណ.វ.សក.

# សេចក្តីណែនាំ
## ស្តីពី
## ការជំរុញបន្ថែមការអនុវត្តវិធានការបន្ទាន់សម្រាប់ការបង្ការ និងទប់ស្កាត់ការរីករាលដាលវីរុសកូវីដ-១៩ ក្នុង "ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ"

យោងតាមបទបញ្ជានិងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីយប់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ដើម្បីចូលរួមបង្ការនិងទប់ស្កាត់វីរុសកូវីដ-១៩ ក្នុង "ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ" ដែលបាននិងកំពុងមានការកើនឡើងខ្លាំងនាពេលបច្ចុប្បន្ននៅតាមបណ្តារាជធានី-ខេត្តពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ក្រសួងសាធារណការនិងដឹកជញ្ជូន សូមដាក់ចេញនូវវិធានការបន្ទាន់និងម៉ឺងម៉ាត់ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រីរាជការក្រោមឱវាទទាំងអស់ ឱ្យចូលរួមអនុវត្តនូវយន្តការដូចខាងក្រោម៖

១- គ្រប់អគ្គនាយកដ្ឋាន/អង្គភាព ត្រូវកាត់បន្ថយចំនួនបុគ្គលិកមន្ត្រីរាជការ ដែលត្រូវមកបំពេញការងារនៅទីស្តីការក្រសួង/អង្គភាព ដោយជំនួសមកវិញនូវការបំពេញការងារពីផ្ទះរៀងៗខ្លួន តាមប្រព័ន្ធអនឡាញ(Online) ប៉ុន្តែត្រូវរៀបចំឱ្យមានបុគ្គលិកមន្ត្រីរាជការប្រចាំការប្តូរវេនគ្នានៅតាមបណ្តាអង្គភាពនីមួយៗក្នុងចំនួនតិចត្រឹមកម្រិត **១០ភាគរយ** ប៉ុណ្ណោះ រហូតដល់មានការជូនដំណឹងជាថ្មី។

២- គ្រប់អគ្គនាយកដ្ឋាន/អង្គភាព ត្រូវបន្តជំរុញឱ្យបុគ្គលិកមន្ត្រីរាជការក្រោមឱវាទទាំងអស់ ចូលរួមបំពេញទម្រង់ឌីជីថលរាយការណ៍ពីស្ថានភាពសុខភាពផ្ទាល់ខ្លួនជារៀងរាល់ថ្ងៃជាប្រចាំ តាមរយៈ http://trace.covid19.mpwt.gov.kh ឬស្កេន QR Code ដែលបាននិងកំពុងអនុវត្តកន្លងមក ទោះបីជាបំពេញការងារពីផ្ទះក៏ដោយ។

៣- **នាយកដ្ឋានបុគ្គលិក** ត្រូវពិនិត្យនិងតាមដានទិន្នន័យនៃការរាយការណ៍អំពីស្ថានភាពសុខភាពរបស់បុគ្គលិកមន្ត្រីរាជការ និងធ្វើការទាក់ទងបន្ទាន់ប្រសិនបើមានករណីសង្ស័យណាមួយត្រូវបានរាយការណ៍ និងត្រូវសហការជាមួយ **នាយកដ្ឋានព័ត៌មានវិទ្យានិងទំនាក់ទំនងសាធារណៈ** ដើម្បីរៀបចំរបាយការណ៍លទ្ធផលនៃការតាមដានសុខភាពបុគ្គលិកមន្ត្រីរាជការ តាមរយៈការបំពេញទម្រង់ឌីជីថលខាងលើនេះ ជូនថ្នាក់ដឹកនាំក្រសួងឱ្យបានទៀងទាត់ជាប្រចាំ។

៤- ករណីមានការសង្ស័យ ឬសភាពមិនប្រក្រតីដែលជារោគសញ្ញានៃជំងឺកូវីដ-១៩ បុគ្គលិកមន្ត្រីរាជការត្រូវរាយការណ៍មក **នាយកដ្ឋានបុគ្គលិក** តាមរយៈលេខទូរស័ព្ទ 011 958 311 ឬទូរស័ព្ទទៅលេខ **១១៥** ជាបន្ទាន់។

៥- ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រីរាជការដែលត្រូវប្រចាំការនៅអង្គភាពនីមួយៗ ត្រូវបន្តចូលរួមស្កេន QR Code "ទប់ស្កាត់មេរោគកូវីដ-១៩" ដែលបានបិទផ្សព្វផ្សាយនៅតាមច្រកចេញ-ចូល **អគាររដ្ឋបាលកណ្តាល** អគារ**ក** អគារ**ខ** អគារសាលប្រជុំ និងវិទ្យាស្ថាន តេជោសែន សាធារណការ និងដឹកជញ្ជូន។

៦- **នាយកដ្ឋានរដ្ឋបាល** ត្រូវគ្រប់គ្រងច្រកចេញ-ចូលទាំងអស់ ដោយកំណត់ឱ្យមានការវាស់កម្តៅ និងពាក់ម៉ាស់ជាប់ជាប្រចាំ ក្នុងករណីមិនអនុវត្តតាម មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណទីស្តីការក្រសួងជាដាច់ខាត។

៧- គ្រប់អង្គភាពទាំងអស់ ជាពិសេស បុគ្គលិកមន្ត្រីរាជការដែលធ្វើការដោយផ្ទាល់ជាមួយឯកសារតាមច្រកចេញ-ចូល ឬមន្ត្រីចរាចរឯកសារ ត្រូវស្អែនសម្លាប់មេរោគលើគ្រប់ឯកសារទាំងអស់ឱ្យបានរួចរាល់ មុននឹងបញ្ជូនឯកសារទាំងអស់នោះទៅតាមនីតិវិធីមកថ្នាក់ដឹកនាំ ឬអង្គភាពពាក់ព័ន្ធ។ ក្នុងករណីខ្លះ ត្រូវជំរុញការដាក់ឆ្លងឯកសារ និងបែងចែកឯកសារតាមប្រព័ន្ធឌីជីថល(Telegram)។

៨- ត្រូវបន្តរឹតបន្តឹងការប្រុងប្រយ័ត្ន និងចូលរួមអនុវត្តឱ្យបានហ្មត់ចត់ និងម៉ឺងម៉ាត់បំផុតនូវ **វិធានការ ៣-ការពារ** និង **៣-កុំ** រួមមានដូចជា៖ ត្រូវពាក់ម៉ាស់ ត្រូវលាងសម្អាតដៃ ត្រូវរក្សាគម្លាតសង្គមនិងគម្លាតបុគ្គល *(ចាប់ពី១,៥ម៉ែត្រឡើងទៅ)*, កុំចូលទៅកន្លែងបិទជិត គ្មានខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់ច្រើនពេក កុំទៅកន្លែងមានមនុស្សច្រើន កុំប៉ះពាល់គ្នា-ចាប់ដៃគ្នា-កៀកស្មាគ្នា-អោបគ្នាជាដើម។

៩- ត្រូវបន្តផ្អាកជាបណ្តោះអាសន្ននូវកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬការជួបជុំនានា។ ចំពោះការងារចាំបាច់ដែលអាក់ខានមិនបាន ត្រូវបានអនុញ្ញាតឱ្យរៀបចំតាមប្រព័ន្ធVideo Conference។

ទទួលបានសេចក្តីណែនាំនេះ ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រីរាជការក្រោមឱវាទទាំងអស់ ត្រូវចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងសហការអនុវត្តឱ្យបានម៉ឺងម៉ាត់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ១១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ស៊ុន ចាន់ថុល**

កន្លែងទទួល៖
- ការិយាល័យ ឯកឧត្តម-លោកជំទាវថ្នាក់ដឹកនាំក្រសួង
- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- គ្រប់អគ្គនាយកដ្ឋាន/អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ-កាលប្បវត្តិ

# តាមដាន
# និងរាយការណ៍
## ប្រចាំថ្ងៃដើម្បីទប់ស្កាត់ជម្ងឺ
## កូវីដ-១៩ (COVID-19)

វីដេអូណែនាំ

trace.covid19.mpwt.gov.kh/guideline



ស្កេនទីនេះ

trace.covid19.mpwt.gov.kh

1275